# ចំរៀង HOH

I ឱ! កំពង់ធំ ជំរុំដួងចិត្ត ខ្ញុំឃ្លាតឆ្ងាយពិត តែចិត្តនឹកគិត មិនអាចភ្លេចឡើយ អើយ
ធ្លាប់បានរស់នៅ យូរខែឆ្នាំហើយ ចងចាំមិនដែលភ្លេចឡើយ អនុស្សាវរីយ៍ កាលពីក្មេងវ័យ ។

I I នឹកញាតិបងប្អូន ដែលធ្លាប់ជិតស្និទ្ធ នឹកគ្រូនឹកមិត្ត ដែលធ្លាប់ជួបជិត នៅក្នុងសាលា អើយ
ធ្លាប់បានសាសង ល្បងលេងរោហា ធ្លាប់បានលេងល្បែងកីឡា រួមគ្នាធ្វើការសែនសុខសប្បាយ ។

R ចប់វិទ្យាល័យ បន្តវិជ្ជា យើងបានឃ្លាតឃ្លា ចេញឆ្ងាយពីគ្នា ឆ្ងាយពីភូមិឋាន
ខានជួបមុខគ្នា លេងល្បែងកំសាន្ត ព្រោះចិត្តប្រាថ្នាចង់បាន អនាគតល្អ តទៅថ្ងៃមុខ ។

I I I នៅពេលរៀនចប់ ចាប់ចេញធ្វើការ មិនដឹងថ្ងៃណា នឹងមានវាសនា បានជួបជួន អើយ
តែទោះនៅឆ្ងាយ ក៏ខំខ្វាប់ខ្លួន ជួបជុំឥតមានធុញទ្រាន់ នាំគ្នារួបរួម ខិតខំធ្វើការ ។

R ឥឡូវស-មាគមបានបង្កើត "ជួយស្រុកកំណើត" យើងធ្វើឱ្យកើត ជួយស្រុកភូមិយើង
ចូលរួមគ្រប់គ្នា ដោយមិនរើសអើង ជួយដល់កំពង់ធំយើង អភិវឌ្ឍន៏អប់រំ និងកីឡា ។

IV បណ្តុះបណ្តាលយុវ-ជនខ្មែរ ឱ្យគេពូកែ ចេះគិតចេះកែ ចេះធ្វើការ អើយ
អភិវឌ្ឍន៏ភូមិស្រុកជូនជាតិខេមរា ចូលរួមលើកស្ទួយនិងស្តារ ដល់ជោគវាសនាកម្ពុជាយើង ។